# Monthly Report Volume 44

August 2025

## Project Activities in August:

- 7th : Monthly Meeting with JICA HQ / Cambodia Office
- 14th : 2nd Orientation Meeting for Battambang PTMT
- 27th : Orientation Meeting for Kampong Cham PTMT

## សកម្មភាពគម្រោងប្រចាំខែសីហា៖

- ថ្ងៃទី៧៖ ការប្រជុំប្រចាំខែជាមួយ ការិយាល័យកណ្ដាល JICA និងការិយាល័យ JICA នៅប្រទេសកម្ពុជា
- ថ្ងៃទី១៤៖ ការប្រជុំតម្រង់ទិសលើកទី២សម្រាប់ក្រុមការងារគ្រប់គ្រងការបណ្ដុះបណ្ដាល ខេត្តបាត់ដំបង (BTB-PTMT)
- ថ្ងៃទី២៧៖ ការប្រជុំតម្រង់ទិសសម្រាប់ក្រុមការងារគ្រប់គ្រងការបណ្ដុះបណ្ដាល ខេត្តកំពង់ចាម (KC-PTMT)

## 2nd Orientation Meeting for Battambang Provincial Training Management Team (BTB-PTMT)

## ការប្រជុំតម្រង់ទិសលើកទី២សម្រាប់ក្រុមការងារគ្រប់គ្រងការបណ្ដុះបណ្ដាល ខេត្តបាត់ដំបង (BTB-PTMT)

On 14th August 2025, the second orientation meeting for the Battambang Provincial Training Management Team (BTB-PTMT) was held via Zoom, attended by all nine PTMT members and the technical team of the Project. In order to ensure the smooth and effective implementation of INSET in the Battambang province scheduled to begin in September 2025.

The Project provided an overview of the e-learning platform, including trainee registration, trainer and admin login procedures, and administrative tasks.

We believe that this collaborative approach will enhance the training implementation's effectiveness, and the PTMT team will be implementing this INSET independently going forward in the future.

នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៥ កិច្ចប្រជុំតម្រង់ទិសលើកទី ២ សម្រាប់ក្រុមការងារគ្រប់គ្រងការបណ្ដុះបណ្ដាលខេត្តបាត់ដំបង (BTB-PTMT) បានធ្វើឡើងតាមរយៈ Zoom ដោយមានការចូលរួមពីសមាជិក PTMT ទាំងប្រាំបួនរូប និងក្រុមការងារបច្ចេកទេសគម្រោង ក្នុងគោលបំណងដើម្បីធានាឱ្យការអនុវត្ត ការរៀបចំវគ្គបណ្ដុះបណ្ដាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាក (INSET) ដែលគ្រោងនឹងចាប់ផ្ដើមនៅខែកញ្ញា ឆ្នាំ២០២៥ នៅខេត្តបាត់ដំបង មានភាពរលូន និងប្រកបដោយប្រសិទ្ធភាព។

គម្រោងបានបង្ហាញទិដ្ឋភាពទូទៅនៃវេទិកា E-learning រួមទាំងការចុះឈ្មោះសិក្ខាកាម នីតិវិធីក្នុងការចូលជាអ្នកគ្រប់គ្រង និងក្នុងនាមជាគ្រូ និងកិច្ចការងាររដ្ឋបាលទូទៅ។

យើងជឿជាក់ថាវិធីសាស្ត្រក្រោមកិច្ចសហការនេះ នឹងជួយបង្កើនប្រសិទ្ធភាពនៃការអនុវត្តការបណ្ដុះបណ្ដាល ហើយក្រុមការងារ PTMT នឹងអនុវត្ត INSET នេះដោយឯករាជ្យឆ្ពោះទៅមុខនាពេលអនាគត។



Meeting with BTB-PTMT

## The Orientation Meeting for Kampong Cham Provincial Training Management Team (KC-PTMT)

## ការប្រជុំតម្រង់ទិសសម្រាប់ក្រុមការងារគ្រប់គ្រងការបណ្ដុះបណ្ដាល ខេត្តកំពង់ចាម (KC-PTMT)

On 27th August 2025, an online orientation meeting was held via Zoom for the Kampong Cham Provincial Training Management Team (KC-PTMT), attended by the PHD Director, PTMT members, and the project's technical team. The meeting focuses on transferring responsibility from the project to the province for organizing the upcoming INSET, set to begin in October 2025.

The project explained the PTMT's main roles and responsibilities, including managing INSET activities, supporting the e-learning platform, handling CCN registration, and carrying out administrative tasks.

This meeting highlighted the PTMT's key role in leading INSET activities and strengthened their ownership and readiness to take full responsibility in their province.

នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៥ កិច្ចប្រជុំតម្រង់ទិសសម្រាប់ក្រុមការងារគ្រប់គ្រងការបណ្ដុះបណ្ដាលខេត្តកំពង់ចាម (KC-PTMT) ត្រូវបានធ្វើឡើងតាមរយៈ Zoom ដោយមានការអញ្ជើញចូលរួមពីឯកឧត្តមប្រធាន មន្ទីរសុខាភិបាលខេត្ត និងសមាជិក PTMT ទាំង១៤រូប និងក្រុមការងារបច្ចេកទេសគម្រោង។ កិច្ចប្រជុំបានផ្ដោតសំខាន់លើការប្រគល់ភារៈកិច្ចពីគម្រោងទៅក្រុមការងារថ្នាក់ខេត្តក្នុងការរៀបចំវគ្គបណ្ដុះបណ្ដាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាក (INSET) ដែលគ្រោងនឹងចាប់ផ្ដើមនៅខែតុលា ឆ្នាំ២០២៥ ខាងមុខនេះ។

គម្រោងបានពន្យល់ពីតួនាទី និងទំនួលខុសត្រូវសំខាន់ៗរបស់ PTMT រួមទាំងការគ្រប់គ្រងសកម្មភាព INSET ការកំណត់មន្ត្រីដែលទទួលបន្ទុកសម្រាប់ការចុះឈ្មោះនៅគណៈគិលានុបដ្ឋាកកម្ពុជា (CCN) និងការជួយសម្របសម្រួល E-learning platform និងកិច្ចការងាររដ្ឋបាលទូទៅ។

កិច្ចប្រជុំនេះបានបញ្ជាក់ពីតួនាទីស្នូលរបស់ក្រុម PTMT ក្នុងការគ្រប់គ្រងសកម្មភាព INSET និងបានពង្រឹងភាពជាម្ចាស់ និងការត្រៀមខ្លួនក្នុងការទទួលខុសត្រូវពេញលេញនៅក្នុងខេត្តរបស់ពួកគេ។



Meeting with KC-PTMT

## UPCOMING ACTIVITIES IN SEPTEMBER

- 8th: Monthly Meeting with JICA HQ / Cambodia Office
- 10th – 11th : INSET in BTB of Nursing Ethics & Nursing Management and Leadership
- 19th : Study tour (Red Cross College of Nursing)

## សកម្មភាពនាពេលខាងមុខក្នុងខែកញ្ញា

- ថ្ងៃទី៨៖ កិច្ចប្រជុំប្រចាំខែជាមួយ JICA HQ/Cambodia Office
- ថ្ងៃទី១០-១១៖ ការបណ្ដុះបណ្ដាល INSET ក្នុងខេត្តបាត់ដំបង វគ្គសីលធម៌ នៃការថែទាំ វគ្គ ការគ្រប់គ្រងការថែទាំ និងភាពជាអ្នកដឹកនាំ
- ថ្ងៃទី១៩៖ ទស្សនៈកិច្ចសិក្សា (Red Cross College of Nursing)


## CONTACT INFORMATION

**Email:** info@jicastrings.com

**Project Office:**

- **Ministry of Health (MoH)**

Department of Human Resource Development (HRDD)
No. 80, Samdach Penn Nouth Blvd (289), Sangkat Beoungkak 2, Tuol Kork District, Phnom Penh

- **National Maternal and Child Health Center (NMCHC)**

N° 31A, Rue de France (St. 47), Sangkat Sras Chork, Daun Penh District, Phnom Penh


Scan here to find out more about us:

JICA's FB Page

Project's Homepage